# ខ្លឹមសារសង្ខេបសាលដីកាលេខ៦ (២០២៣)

**ពាក្យគន្លឹះ៖** មោឃៈភាព កំណត់ហេតុស្តាប់ចម្លើយ នីតិវិធីកុមារមេត្រី

សាលដីកានេះអាចរកបានតាម៖ [សាលដីកា ផឿង ម៉ម ពន្លឺ (measboralaws.com)]

## ក.ប្រវត្តិនិងនីតិវិធី

អនីតិជនអាយុ១៧ ត្រូវបានឃាត់ខ្លួន និងកត់កំណត់ហេតុដោយនគរបាលយុត្តិធម៌។ គាត់ត្រូវបានចោទពីបទប្រើប្រាស់និងជួញដូរសារធាតុញៀនតាមមាត្រា៤០និង៤៥នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀនឆ្នាំ២០១២។

ក្នុងអំឡុងពេលឃាត់និងសាកសួរ មិនមានវត្តមានម្តាយឬមេធាវីទេ។ នេះជាមូលហេតុនៃបណ្តឹងមោឃៈភាពដោយមេធាវីការពារសិទ្ធិ ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ សុំមោឃៈភាពឯកសារចម្បង និងពាក់ព័ន្ធសរុបចំនួន៥។ មេធាវី បានផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌនិងជាពិសេសមាត្រា២២និង២៦នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

ព្រះរាជអាជ្ញារងបានអះអាងថា ឯកសារចំនួនបី ត្រូវបានធ្វើឡើងខុសនឹងមាត្រា១០៩នៃក្រមនីតិវិធីព្រហ្មទណ្ឌគួរទុកជាមោឃៈ ចំណែក២ទៀត ទុកជូនក្រុមប្រឹក្សាសម្រេច។

ក្រុមប្រឹក្សាបានយោងដល់មាត្រា៩៣និង៩៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា២២នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ ក្រោយពិចារណាឃើញថា ក្នុងអំឡុងពេលសាកសួរ ពុំបានអនុញ្ញាតឲ្យម្តាយចូលរួម ខុសនឹងមាត្រា២២ ដែលនាំឲ្យមានមោឃៈដាច់ខាត ក្រុមប្រឹក្សាសម្រេចថា កំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ ត្រូវមោឃៈភាព។

## ខ. កំណត់សំគាល់

*យោងតាមមាត្រា២២នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន តម្រូវឲ្យមានមេធាវីដាច់ខាតនៅពេលសួរចម្លើយជនត្រូវចោទ។....*(ទំ.៦)។ ឃ្លានេះមានខ្លឹមសារច្បាស់លាស់ ថាសិទ្ធិមានមេធាវី ជាសិទ្ធិដាច់ខាត ដែលនគរបាលត្រូវគោរព ប្រសិនបើមិនចង់ឲ្យកំណត់ហេតុ ត្រូវបានមោឃៈភាពនាពេលក្រោយ។

ក្រុមប្រឹក្សាបានយោងដល់មាត្រា៩៨នៃក្រមនីតិវិធីព្រហ្មទណ្ឌក្នុងរឿងនេះ ដែលហាក់បង្ហាញនូវមន្ទិល អំពីការចាប់ផ្តើមអនុវត្តសិទ្ធិមានមេធាវីរបស់អនីតិជន ក្រោយ២៤ម៉ោងដូចករណីនីតិជនល្មើសច្បាប់ឬមានតាំងពីដើមដំបូងនៃនីតិវិធី?។ អ្វីគួរឲ្យកត់សំគាល់ មាត្រា៦នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចែងថា អនីតិជនមានសិទ្ធិជំនួយផ្លូវច្បាប់ (មេធាវី)តាំងពីនីតិវិធីដំបូង។

សូមធ្វើការស្រាវជ្រាវបន្តបញ្ហានេះ និងរងចាំតាមដានខ្លឹមសារសម្រេចក្រោយៗទៀត។